KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការបើក និងបិទគណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ខបតើរេត

Terms and Conditions for Opening and Closing a Term Deposit Account via KB PRASAC Corporate

ចោះពុម្ពលើកទី ២

មាតិកា

1. លក្ខខណ្ឌទូទៅ 1
2. និយមន័យនៃពាក្យគន្លឹះ 1
3. លក្ខខណ្ឌបើកគណនីបញ្ញើមានកាលកំណត់ 2
   - 3.1. ម៉ោងប្រតិបត្តិការ 2
   - 3.2. លក្ខខណ្ឌតម្រូវនៃគណនីប្រភព 2
   - 3.3. រូបិយប័ណ្ណ 3
   - 3.4. ទំហំទឹកប្រាក់ដាក់បញ្ញើ និងចំនួនគណនី 3
   - 3.5. រយៈពេលដាក់ប្រាក់បញ្ញើ 3
   - 3.6. អត្រាការប្រាក់ 3
   - 3.7. ពន្ធកាត់ទុក (ពន្ធលើការប្រាក់) 3
   - 3.8. ប្រភេទគណនីបញ្ញើមានកាលកំណត់ 4
   - 3.9. លក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់ 4
   - 3.10. ការផ្លាស់ប្តូរលក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់ 5
   - 3.11. ថ្ងៃប្រសិទ្ធភាពនៃការបើកគណនី 5
   - 3.12. កាលបរិច្ឆេទដល់កាលកំណត់នៃគណនី 5
   - 3.13. វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ ឬ របាយការណ៍គណនី 6
4. ការដាក់ប្រាក់ 6
5. ការដកប្រាក់ 6
6. លក្ខខណ្ឌនៃការស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ 6
   - 6.1. ការស្នើសុំបិទគណនីនៅតាមសាខាខេប៊ីប្រាសាក់ 6
   - 6.2. ការស្នើសុំបិទគណនីតាមរយៈសេវាខេប៊ីប្រាសាក់ឌបអើរេត 7
7. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី 8
8. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់ 8
9. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម 9
10. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា លក្ខខណ្ឌ និងការជូនដំណឹង 9
11. ច្បាប់ និងការដោះស្រាយវិវាទ 10
12. វិភាគភាព 10
13. ភាសា 10

1. លក្ខខណ្ឌទូទៅ

1.1. លក្ខខណ្ឌនៃការបើក និងបិទគណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត ហៅកាត់ថា **«លក្ខខណ្ឌ»** គឺជាកិច្ចព្រមព្រៀងរវាង លោក-លោកស្រី ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក ហៅកាត់ថា **«ខេប៊ីប្រាសាក់»** ក្នុងការប្រើប្រាស់សេវាកម្មនេះជាមួយខេប៊ីប្រាសាក់។

1.2. លោក-លោកស្រី ត្រូវអានលក្ខខណ្ឌទូទៅនេះដោយប្រុងប្រយ័ត្ន មុននឹងចុច **«យល់ព្រម»** ដើម្បីបន្តលើការបើក និង បិទគណនីបញ្ញើមានកាលកំណត់ តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត។

1.3. នៅពេល លោក-លោកស្រី បានចុច **«យល់ព្រម»** មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ និងទទួលខុសត្រូវលើការប្រើប្រាស់គណនីបញ្ញើមានកាលកំណត់រួមមាន ការបើក ការកែប្រែ និងការបិទគណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត

2. និយមន័យនៃពាក្យគន្លឹះ

❖ ពាក្យ **«លោក-លោកស្រី»** ៖ សំដៅដល់ ម្ចាស់គណនី ឬ អ្នកមានសិទ្ធិក្នុងគណនី ដែលប្រើប្រាស់គណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត។

❖ សេវាខេប៊ីប្រាសាក់ឌបភើរេត ៖ សំដៅលើ សេវាមួយប្រភេទដែលអនុញ្ញាតឱ្យ លោក-លោកស្រី អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ លើគណនីរបស់ខ្លួនបានដោយសុវត្ថិភាពនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា (24/7) តាមរយៈខេប៊ីប្រាសាក់ឌបភើរេតវែប (Internet Browser)។

❖ គណនីបញ្ញើមានកាលកំណត់ ៖ គឺជាគណនីប្រាក់បញ្ញើសន្សំ ដែលមានរយៈពេលជាក់លាក់ក្នុងការដាក់ប្រាក់បញ្ញើ ហើយគណនីនេះទទួលបានអត្រាការប្រាក់ខ្ពស់ទៅតាមរយៈពេលដាក់ប្រាក់បញ្ញើនីមួយៗ។

❖ គណនីប្រភព ៖ គឺជាគណនីគោល សម្រាប់ការដកប្រាក់ដើមនៅពេលបើកគណនី ឬទូទាត់ការប្រាក់ និងប្រាក់ដើមចូលវិញនៅពេលបិទគណនីបញ្ញើមានកាលកំណត់ ឬ ទទួលការប្រាក់ប្រចាំខែជាដើម។ សម្រាប់ការបើក ឬ បិទគណនី ឬ ធ្វើប្រតិបត្តិការផ្សេងៗនៅលើគណនីបញ្ញើមានកាលកំណត់ នៅតាមបញ្ជរបេឡា គឺត្រូវគោរពទៅតាម **គំរូហត្ថលេខា** និង **លក្ខខណ្ឌប្រតិបត្តិការ** នៃ **គណនីប្រភព** ជាគោល។

❖ របាយការណ៍គណនី ៖ សំដៅលើកំណត់ត្រានៃប្រតិបត្តិការចេញ ឬ ចូលទាំងឡាយនៅក្នុងគណនី។

❖ លក្ខខណ្ឌបន្តតែប្រាក់ដើម ៖ នៅពេលដល់កាលកំណត់នៃគណនីបញ្ញើមានកាលកំណត់ ការប្រាក់នឹងផ្ទេរចូលទៅក្នុងគណនីប្រភព ហើយប្រាក់ដើមនឹងបន្តទៅវគ្គបន្ទាប់ដោយស្វ័យប្រវត្តិ។

- ❖ លក្ខខណ្ឌបន្តទាំងប្រាក់ដើម និងការប្រាក់ ៖ នៅពេលដល់កាលកំណត់នៃគណនីបញ្ញើមានកាលកំណត់ ប្រាក់ដើម និងការប្រាក់ ត្រូវបានបង្ករជាប្រាក់ដើម ហើយបន្តទៅវគ្គបន្ទាប់ដោយស្វ័យប្រវត្តិ។
- ❖ លក្ខខណ្ឌមិនបន្តគណនី ៖ នៅពេលគណនីដល់កាលកំណត់ គណនីបញ្ញើមានកាលកំណត់នឹងត្រូវបានបិទដោយស្វ័យប្រវត្តិ ហើយប្រាក់ដើម និងការប្រាក់ នឹងត្រូវផ្ទេរចូលទៅក្នុងគណនីប្រភពដោយស្វ័យប្រវត្តិ។

3. លក្ខខណ្ឌបើកគណនីបញ្ញើមានកាលកំណត់

លោក-លោកស្រី ត្រូវបញ្ចូលព័ត៌មាន និងជ្រើសរើសលក្ខខណ្ឌសម្រាប់ការបើកគណនីបញ្ញើមានកាលកំណត់ឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

3.1. ម៉ោងប្រតិបត្តិការ

លោក-លោកស្រី អាចបើកគណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ខបភើរេត បានគ្រប់ពេលវេលា (24/7) និងគ្រប់ទីកន្លែង លើកលែងតែមានការជូនដំណឹង ស្តីពីការផ្អាកជាបណ្តោះអាសន្នពីខេប៊ីប្រាសាក់។

3.2. លក្ខខណ្ឌតម្រូវនៃគណនីប្រភព

3.2.1. ដើម្បីបើកគណនីបញ្ញើមានកាលកំណត់បាន លោក-លោកស្រី ត្រូវជ្រើសរើស **គណនីប្រភព** ដែលជាគណនីប្រាក់បញ្ញើសន្សំ ភ្ជាប់នឹងសេវាខេប៊ីប្រាសាក់ខបភើរេត ជាមួយកម្រិតសិទ្ធិប្រើប្រាស់គណនី «ពេញលេញ/Full Access» ដែលអនុញ្ញាតឱ្យ លោក-លោកស្រី អាចធ្វើប្រតិបត្តិការគណនីបានគ្រប់ប្រភេទ។

3.2.2. គណនីប្រភព អាចជា គណនីសន្សំ ឬ គណនីចម្រើនគ្មានកាលកំណត់ ឬ គណនីចម្រើនតាមលំដាប់ ឬ គណនីចរន្ត ឬ គណនីចរន្តព្រីមៀម ឬ គណនីឌីជីថល ឬ គណនីសន្សំពាណិជ្ជកម្ម។ល។

3.2.3. គណនីប្រភព មិនត្រូវបានអនុញ្ញាតឱ្យស្នើសុំបិទឡើយ ប្រសិនបើគណនីនេះមានភ្ជាប់គណនីបញ្ញើមានកាលកំណត់ដែលកំពុងនៅដំណើរការ។

3.2.4. លោក-លោកស្រី យល់ព្រម និងអនុញ្ញាតឱ្យខេប៊ីប្រាសាក់យក **គំរូហត្ថលេខា** និង**លក្ខខណ្ឌប្រតិបត្តិការ** នៃគណនីប្រភព ជាគោល ដើម្បីធ្វើការផ្ទៀងផ្ទាត់ពីភាពជាម្ចាស់គណនី ករណីមានការស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ ឬ ធ្វើប្រតិបត្តិការពាក់ព័ន្ធផ្សេងៗនៅតាមបញ្ជរបេឡា (អាចជាការស្នើសុំលិខិតបញ្ជាក់សមតុល្យគណនី ឬ របាយការណ៍គណនី។ល។)។

3.2.5. ករណីគណនីប្រភព គឺជាគណនីរួម ឬ គណនីនីតិបុគ្គល ដែលមានអ្នកមានសិទ្ធិក្នុងគណនី ចាប់ពី 02 (ពីរ) នាក់ឡើងទៅ នោះ លោក-លោកស្រី ត្រូវទទួលស្គាល់ និងយល់ព្រមថាសមាជិកផ្សេងទៀតក្នុងគណនីរបស់ លោក-លោកស្រី មានសិទ្ធិក្នុងការស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ ឬ ធ្វើប្រតិបត្តិការពាក់ព័ន្ធផ្សេងៗបាន ដោយគោរពទៅតាម **គំរូហត្ថលេខា** និង**លក្ខខណ្ឌប្រតិបត្តិការ**នៃគណនីប្រភព។

3.3. **រូបិយប័ណ្ណ**

3.3.1. លោក-លោកស្រី អាចជ្រើសរើសការបើកគណនីបញ្ញើមានកាលកំណត់ជាមួយរូបិយប័ណ្ណចំនួន 02 (ពីរ) ប្រភេទ រួមមាន៖

1) គណនីប្រាក់រៀល (KHR) និង
2) គណនីប្រាក់ដុល្លារអាមេរិក (USD)

3.3.2. ប្រភេទរូបិយប័ណ្ណនឹងត្រូវបានកំណត់ដោយផ្អែកទៅតាមប្រភេទរូបិយប័ណ្ណនៃគណនីប្រភព។ ដូច្នេះ លោក-លោកស្រី មិនអាចជ្រើសរើសប្រភេទរូបិយប័ណ្ណខុសពីរូបិយប័ណ្ណនៃគណនីប្រភពបានឡើយ។

3.4. **ទំហំទឹកប្រាក់ដាក់បញ្ញើ និងចំនួនគណនី**

3.4.1. ទំហំទឹកប្រាក់បញ្ញើអប្បបរមា សម្រាប់ការបើកគណនីបញ្ញើមានកាលកំណត់ គឺចាប់ពីចំនួន 200,000 រៀល ឬ 50 ដុល្លារអាមេរិក និងមិនកំណត់សម្រាប់អតិថិជនម្នាក់។

3.4.2. មិនមានការកំណត់ទៅលើចំនួនគណនីបញ្ញើមានកាលកំណត់ ដែលត្រូវបានបើកដោយលោក-លោកស្រី តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត ឡើយ។

3.5. **រយៈពេលដាក់ប្រាក់បញ្ញើ**

លោក-លោកស្រី អាចជ្រើសរើសរយៈពេលដាក់ប្រាក់បញ្ញើចាប់ពី **01 ខែ** រហូតដល់ **60 ខែ** ទៅតាមតម្រូវការ និងការបង្ហិលសាច់ប្រាក់ជាក់ស្តែង។

3.6. **អត្រាការប្រាក់**

3.6.1. លោក-លោកស្រី នឹងទទួលបានអត្រាការប្រាក់ទៅតាមជម្រើសនៃរយៈពេលដាក់ប្រាក់បញ្ញើនីមួយៗ ដែលបានជ្រើសរើស។

3.6.2. ការប្រាក់នឹងត្រូវបានបង្គរជាប្រចាំថ្ងៃ និងទូទាត់ចូលទៅក្នុងគណនីប្រភពរបស់លោក-លោកស្រី ជាប្រចាំខែ ឬ នៅចុងគ្រា (ដល់កាលកំណត់) ទៅតាមប្រភេទគណនីបញ្ញើមានកាលកំណត់ដែលលោក-លោកស្រី បានជ្រើសរើស ។

3.6.3. លោក-លោកស្រីអាចស្វែងរកព័ត៌មានអំពីអត្រាការប្រាក់នៃគណនីបញ្ញើមានកាលកំណត់បាននៅពេលបើកគណនីតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត ឬ តាមរយៈវេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ ឬ សាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិត លោក-លោកស្រី បំផុត។

3.7. **ពន្ធកាត់ទុក (ពន្ធលើការប្រាក់)**

3.7.1. លោក-លោកស្រី ទទួលស្គាល់ថារាល់ការប្រាក់ដែលទទួលបានពីការដាក់ប្រាក់បញ្ញើសន្សំនឹងត្រូវជាប់កាតព្វកិច្ចពន្ធកាត់ទុក ឬ ពន្ធផ្សេងៗតាមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តិជាធរមាន។

3.7.2. លោក-លោកស្រី ទទួលស្គាល់ថា **ពន្ធកាត់ទុក** ជាបន្ទុករបស់ លោក-លោកស្រី និងយល់ព្រមឱ្យ ខេប៊ីប្រាសាក់ ធ្វើការទូទាត់ **ពន្ធកាត់ទុក** ចេញពីគណនីបញ្ញើមានកាលកំណត់របស់ លោក-លោកស្រី ដោយស្វ័យប្រវត្តិនៅរាល់ពេលដែល ខេប៊ីប្រាសាក់ បានបញ្ចូលការប្រាក់ទៅក្នុងគណនីនីមួយៗរបស់ លោក-លោកស្រី។

3.7.3. អត្រាពន្ធកាត់ទុកត្រូវបានកំណត់ ទៅតាមអត្រាពន្ធ ដូចខាងក្រោម៖

- **6% សម្រាប់និវាសនជន** ឬ
- **14% សម្រាប់អនិវាសនជន**

3.8. **ប្រភេទគណនីបញ្ញើមានកាលកំណត់**

លោក-លោកស្រី អាចជ្រើសរើសបើកគណនីបញ្ញើមានកាលកំណត់ ចំនួន 02 (ពីរ) ប្រភេទរួមមាន៖

- **គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ប្រចាំខែ៖** ជាប្រភេទគណនីដែលលោក-លោកស្រី នឹងទទួលបានការប្រាក់ជាប្រចាំខែ ដែលការប្រាក់នឹងបញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងគណនីប្រភព។
- **គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ចុងគ្រា៖** លោក-លោកស្រី នឹងទទួលបានការប្រាក់នៅពេលគណនីដល់កាលកំណត់ ហើយការប្រាក់នឹងបញ្ចូលទៅក្នុងគណនីប្រភព ឬ បង្គរជាប្រាក់ដើមអាស្រ័យទៅលើការជ្រើសរើស **លក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់**។

3.9. **លក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់**

3.9.1. នៅពេលបើកគណនី លោក-លោកស្រី អាចជ្រើសរើសលក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់ ទៅតាមជម្រើសដូចខាងក្រោម៖

1) បន្តប្រាក់ដើម និងការប្រាក់ (Rollover Principle and Interest)
2) បន្តតែប្រាក់ដើម (Rollover Principle only)
3) មិនបន្តគណនី (Close on Maturity)

3.9.2. ករណីលោក-លោកស្រី ជ្រើសរើសលក្ខខណ្ឌបន្តគណនីដោយស្វ័យប្រវត្តិ (បន្តប្រាក់ដើម និងការប្រាក់ ឬ បន្តតែប្រាក់ដើម) ប្រសិនបើពុំមានការស្នើសុំផ្លាស់ប្តូរលក្ខខណ្ឌផ្សេងៗនៅពេលគណនីដល់កាលកំណត់ នោះមានន័យថា លោក-លោកស្រី យល់ព្រមបន្តគណនីបញ្ញើមានកាលកំណត់ទៅវគ្គបន្ទាប់ទៅតាមរយៈពេល និងលក្ខខណ្ឌដាក់ប្រាក់បញ្ញើដូចមុន ហើយព្រមទទួលយកអត្រាការប្រាក់ស្តង់ដារដែល ខេប៊ីប្រាសាក់ កំពុងមានជាធរមាន។

3.9.3. ករណី លោក-លោកស្រី ជ្រើសរើសប្រភេទ **«គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ចុងគ្រា»** នោះ លោក-លោកស្រី អាចជ្រើសរើសលក្ខខណ្ឌបន្ត ឬ មិនបន្តគណនីណាមួយក្នុងចំណោមលក្ខខណ្ឌបន្តទាំង 03 (បី) ដូចបញ្ជាក់ក្នុងចំណុច 3.9.1 ខាងលើ។

3.9.4. ករណីលោក-លោកស្រី ជ្រើសរើសប្រភេទ **«គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ប្រចាំខែ»** នោះលោក-លោកស្រី អាចជ្រើសរើសលក្ខខណ្ឌបន្តគណនីបានតែ 02 (ពីរ) ជម្រើសប៉ុណ្ណោះ គឺបន្តតែប្រាក់ដើម (Rollover Principle only) ឬ មិនបន្តគណនី (Close on Maturity)។ ករណីនេះ លោក-លោកស្រី មិនអាចជ្រើសរើសលក្ខខណ្ឌ **បន្តប្រាក់ដើម** និង **ការប្រាក់** បានឡើយ ពីព្រោះការប្រាក់ត្រូវបានបញ្ចូលទៅក្នុងគណនីប្រភពជាប្រចាំខែរួចរាល់។

3.10. **ការផ្លាស់ប្តូរលក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់**

3.10.1. លោក-លោកស្រី អាចធ្វើការផ្លាស់ប្តូរលក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់បានដោយខ្លួនឯង តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត រួមទាំងគណនីបញ្ញើមានកាលកំណត់ដែលបានបើកនៅតាមសាខាខេប៊ីប្រាសាក់ និងបើកតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត ដោយលោក-លោកស្រីអាចធ្វើការប្តូរដូចខាងក្រោម៖

1) **គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ចុងគ្រា** អតិថិជនអាច៖
   - ⇨ ប្តូរពីលក្ខខណ្ឌ «បន្តប្រាក់ដើម និងការប្រាក់ (Rollover Principle and Interest)» ទៅ/មក «បន្តតែប្រាក់ដើម (Rollover Principle only)» ឬ «មិនបន្តគណនី (Close on Maturity)»
   - ⇨ ប្តូរពីលក្ខខណ្ឌ «បន្តតែប្រាក់ដើម/Rollover Principal only» ទៅ/មក «មិនបន្តគណនី/ Close on Maturity»
2) **គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ប្រចាំខែ** អតិថិជនអាច៖
   - ⇨ ប្តូរពីលក្ខខណ្ឌ «បន្តតែប្រាក់ដើម (Rollover Principle only)» ទៅ «មិនបន្តគណនី (Close on Maturity)»
   - ⇨ ប្តូរពីលក្ខខណ្ឌ «មិនបន្តគណនី (Close on Maturity)» ទៅ «បន្តតែប្រាក់ដើម (Rollover Principal only)»

3.10.2. មិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរលក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់ ដែលកំពុងជាប់បង្ខាំង ឬ បង្កកឡើយ។

3.11. **ថ្ងៃប្រសិទ្ធភាពនៃការបើកគណនី**

3.11.1. ថ្ងៃប្រសិទ្ធភាព (Effective Date) នៃការបើកគណនីបញ្ញើមានកាលកំណត់ គឺនៅថ្ងៃជាក់ស្តែងដែលលោក-លោកស្រី បានបើកគណនីបញ្ញើមានកាលកំណត់ តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត។

3.11.2. ករណី លោក-លោកស្រី បើកគណនីបញ្ញើមានកាលកំណត់នៅថ្ងៃចុងសប្តាហ៍ ឬ ថ្ងៃឈប់សម្រាក ឬ បន្ទាប់ពីប្រព័ន្ធធនាគារស្នូលរបស់ ខេប៊ីប្រាសាក់ បានធ្វើការបិទបញ្ជីជាប្រចាំថ្ងៃ (EOD / Closing Business Day) នោះថ្ងៃប្រសិទ្ធភាពនៃការបើកគណនី (Effective Date) នឹងត្រូវ **លើកទៅថ្ងៃធ្វើការបន្ទាប់ (Next Working Day)** ដោយស្វ័យប្រវត្តិ។

3.12. **កាលបរិច្ឆេទដល់កាលកំណត់នៃគណនី**

3.12.1. កាលបរិច្ឆេទដល់កាលកំណត់ ឬ ថ្ងៃផុតកំណត់ (Maturity Date) នៃគណនីបញ្ញើមានកាលកំណត់ត្រូវបានកំណត់ដោយស្វ័យប្រវត្តិពីប្រព័ន្ធ ដោយផ្អែកទៅតាម **«រយៈពេលដាក់ប្រាក់បញ្ញើ»** នីមួយៗ ដែលលោក-លោកស្រី បានជ្រើសរើស។

3.12.2. ករណី កាលបរិច្ឆេទដល់កាលកំណត់ ប៉ះចំថ្ងៃចុងសប្តាហ៍ ឬ ថ្ងៃឈប់សម្រាក នោះកាលបរិច្ឆេទដល់កាលកំណត់ (Maturity Date) នឹងត្រូវលើកថយក្រោយឱ្យចំថ្ងៃធ្វើការ ដោយស្វ័យប្រវត្តិ។

3.13. **វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ ឬ របាយការណ៍គណនី**

3.13.1. លោក-លោកស្រី អាចពិនិត្យព័ត៌មាននៃគណនីបញ្ញើមានកំណត់ដែលបានបើក ឬ ប្រតិបត្តិការគណនីផ្សេងៗតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

3.13.2. លោក-លោកស្រី អាចធ្វើការបោះពុម្ព **វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់** ដែលជាព័ត៌មានលម្អិតនៃគណនីបញ្ញើមានកាលកំណត់ បានដោយខ្លួនឯង ដោយគ្រាន់តែទាញយកព័ត៌មាននៃគណនីបញ្ញើមានកាលកំណត់នីមួយៗពីសេវាខេប៊ីប្រាសាក់ឌបភើរេតរបស់ខ្លួន។

3.13.3. ករណី លោក-លោកស្រី មានបំណងស្នើសុំ **វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់** ឬ របាយការណ៍គណនី ជាច្បាប់ដើម នោះ លោក-លោកស្រី អាចអញ្ជើញមកស្នើសុំនៅសាខា ខេប៊ីប្រាសាក់ ណាមួយដែលនៅជិតបំផុត ដោយការស្នើសុំត្រូវគោរពទៅតាមលក្ខខណ្ឌកំណត់ដោយខេប៊ីប្រាសាក់។

4. ការដាក់ប្រាក់

4.1. ការដាក់ប្រាក់បន្ថែមទៅក្នុងគណនីបញ្ញើមានកាលកំណត់ដែលបានបើករួចរាល់ មិនត្រូវបានអនុញ្ញាតនោះទេ។

4.2. រាល់ការដាក់ប្រាក់បន្ថែម គឺស្មើនឹងការបើកគណនីបញ្ញើមានកាលកំណត់ថ្មីបន្ថែមទៀត ដោយការបើកគណនីត្រូវអនុវត្តទៅតាមលក្ខខណ្ឌបើកគណនីដូចមានចែងនៅក្នុងលក្ខខណ្ឌនេះ។

5. ការដកប្រាក់

រាល់ការស្នើសុំដកប្រាក់ដោយផ្នែកណាមួយ ឬ ទាំងស្រុង ចេញពីគណនីបញ្ញើមានកាលកំណត់ គឺស្មើនឹងការស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ ដោយត្រូវអនុលោមទៅតាម «លក្ខខណ្ឌនៃការស្នើសុំបិទគណនីគណនីបញ្ញើមានកាលកំណត់» ដូចមានចែងនៅក្នុងលក្ខខណ្ឌនេះ។

6. លក្ខខណ្ឌនៃការស្នើសុំបិទគណនីបញ្ញើមានកាលកំណត់

លោក-លោកស្រី អាចស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ទៅតាមមធ្យោបាយណាមួយខាងក្រោម៖

1) ស្នើសុំជាលាយលក្ខណ៍អក្សរនៅតាមសាខាខេប៊ីប្រាសាក់ណាមួយ ឬ
2) បញ្ជូនសំណើស្នើសុំបិទគណនីតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត ឬ
3) គណនីត្រូវបានបិទដោយស្វ័យប្រវត្តិនៅពេលគណនីដល់កាលកំណត់ ករណី លោក-លោកស្រី បានជ្រើសរើសប្រភេទលក្ខខណ្ឌមិនបន្តគណនី (Close on Mature)។

6.1. ការស្នើសុំបិទគណនីនៅតាមសាខាខេប៊ីប្រាសាក់

6.1.1. លោក-លោកស្រី អាចស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ជាលាយលក្ខណ៍អក្សរនៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ។

6.1.2. អ្នកមានសិទ្ធិស្នើសុំបិទគណនី អាចជា លោក-លោកស្រី និង/ឬ អ្នករួមគណនី (ករណីគណនីរួម) និង/ឬ អ្នកមានសិទ្ធិក្នុងគណនីផ្សេងទៀត បើទោះបីជាគណនីបញ្ញើមានកាលកំណត់ត្រូវបានបើកដោយ លោក-លោកស្រី ក៏ដោយ។

6.1.3. ការស្នើសុំបិទគណនី គឺត្រូវយោងទៅតាម **គំរូហត្ថលេខា** និង**លក្ខខណ្ឌប្រតិបត្តិការនៃគណនីប្រភព**។

6.1.4. លោក-លោកស្រី នឹងទទួលបានការប្រាក់ពេញ ករណីស្នើសុំបិទគណនី ដែលដល់កាលកំណត់។

6.1.5. ករណី លោក-លោកស្រី **ស្នើសុំបិទគណនី មុនកាលកំណត់** លោក-លោកស្រី យល់ព្រមចំពោះការខាតបង់ការប្រាក់ដែលនឹងទទួលបាន ហើយ ខេប៊ីប្រាសាក់ រក្សាសិទ្ធិគ្រប់បែបយ៉ាងក្នុងការកំណត់ អត្រាការប្រាក់ដែលត្រូវផ្តល់ជូន លោក-លោកស្រី នៅពេលស្នើសុំបិទគណនី។

6.1.6. បន្ទាប់ពីបិទគណនី ប្រាក់ដើម និងការប្រាក់ នឹងត្រូវបង្វិលចូលទៅក្នុងគណនីប្រភពរបស់លោក-លោកស្រី ហើយ លោក-លោកស្រី អាចធ្វើការត្រួតពិនិត្យបានតាមរយៈរបាយការណ៍គណនី។

6.1.7. ករណី លោក-លោកស្រី **ស្នើសុំបិទ គណនីបញ្ញើមានកាលកំណត់-ចម្រើនការប្រាក់ប្រចាំខែ មុនកាលកំណត់** នោះ លោក-លោកស្រី ត្រូវទូទាត់នូវរាល់ការប្រាក់ទាំងអស់ដែលបានទទួលជាប្រចាំខែត្រលប់មក ខេប៊ីប្រាសាក់ វិញ ដោយយល់ព្រមឱ្យ ខេប៊ីប្រាសាក់ ធ្វើការទូទាត់សាច់ប្រាក់ចេញពីសមតុល្យនៃគណនីបញ្ញើមានកាលកំណត់របស់ លោក-លោកស្រី ដោយស្វ័យប្រវត្តិ។

6.1.8. ប្រសិនបើ លោក-លោកស្រី មានជាប់កាតព្វកិច្ចកម្ចី ដោយដាក់ សមតុល្យនៃគណនីបញ្ញើមានកាលកំណត់ណាមួយជាទ្រព្យធានាកម្ចី នោះ លោក-លោកស្រី អាចស្នើសុំបិទគណនីនោះបាន លុះត្រាតែបានបំពេញកាតព្វកិច្ចទូទាត់សងកម្ចីទាំងមូលរួចរាល់ជាមុនសិន។

6.2. ការស្នើសុំបិទគណនីតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត

6.2.1. លោក-លោកស្រីអាចស្នើសុំបិទគណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត (KB PRASAC Corporate) បានគ្រប់ពេល (24/7) និងគ្រប់ទីកន្លែង ដោយការស្នើសុំត្រូវយោងទៅតាមនីតិវិធីនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឌបភើរេត។

6.2.2. លោក-លោកស្រីអាចស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ ដែលបានបើកនៅ៖

- តាមសាខាខេប៊ីប្រាសាក់ណាមួយ ឬ
- តាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត ឬ
- តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

6.2.3. សំណើសុំបិទគណនីបញ្ញើមានកាលកំណត់របស់លោក-លោកស្រីតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត នឹងត្រូវបានត្រួតពិនិត្យ និងអនុម័ត ដោយ ខេប៊ីប្រាសាក់ នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការ។

6.2.4. ករណីលោក-លោកស្រីស្នើសុំបិទគណនីបញ្ញើមានកាល ចំថ្ងៃឈប់សម្រាក ឬ ថ្ងៃចុងសប្តាហ៍ ឬ ផុតម៉ោងធ្វើការរបស់ខេប៊ីប្រាសាក់ នោះសំណើរបស់លោក-លោកស្រីនឹងត្រូវពិនិត្យ និងអនុម័តនៅថ្ងៃ និងម៉ោងធ្វើការបន្ទាប់ (Next working Day)។

6.2.5. លោក-លោកស្រីមិនអាចស្នើសុំបិទគណនីបញ្ញើមានកាលកំណត់ដែលបានបង្ខាំង ឬ បង្កក ឬ ដាក់ជាទ្រព្យធានាកម្ចីបានឡើយ។

6.2.6. លក្ខខណ្ឌផ្សេងៗ គឺអនុវត្តដូចលក្ខខណ្ឌមានចែងនៅក្នុងលក្ខខណ្ឌនៃការស្នើសុំបិទគណនីនៅតាមសាខាខេប៊ីប្រាសាក់។

7. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី

7.1. លោក-លោកស្រី ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគ្រប់ចំណុចនៅលើលក្ខខណ្ឌនេះ។

7.2. លោក-លោកស្រី ត្រូវប្រកាសដថា លោក-លោកស្រី មានសិទ្ធិគ្រប់គ្រាន់ក្នុងការបើក និងស្នើសុំបិទគណនីបញ្ញើមានកាលកំណត់តាមរយៈសេវាខេប៊ីប្រាសាក់ឧបភោគ និងបានផ្តល់ព័ត៌មានត្រឹមត្រូវ និងថ្មីបំផុតមកខេប៊ីប្រាសាក់។

7.3. លោក-លោកស្រី ត្រូវប្រកាសដថា គណនីប្រភព មានសមតុល្យគ្រប់គ្រាន់ក្នុងការស្នើសុំបើកគណនីបញ្ញើមានកាលកំណត់។

7.4. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យព័ត៌មាន និងលក្ខខណ្ឌនៃការបើកគណនីបញ្ញើមានកាលកំណត់ឱ្យបានត្រឹមត្រូវ មុននឹងសម្រេចលើការអនុម័តប្រតិបត្តិការបើកគណនីបញ្ញើមានកាលកំណត់។ រាល់ការបញ្ចូល ឬជ្រើសរើសលក្ខខណ្ឌបើកគណនីខុសពីគោលបំណងរបស់ខ្លួន ដូចជាការជ្រើសរើសលេខគណនីប្រភពខុស ឬកំណត់ទំហំទឹកប្រាក់បញ្ញើលើស ឬ ខ្វះ។ល។ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

7.5. លោក-លោកស្រី យល់ព្រមពិនិត្យ និងជូនដំណឹងមក ខេប៊ីប្រាសាក់ ស្តីអំពីកំហុសបច្ចេកទេស ឬ ភាពមិនប្រក្រតីណាមួយដែលបានកើតឡើងនៅក្នុងកំឡុង ឬ ក្រោយពេលបើក ឬ បិទគណនីបញ្ញើមានកាលកំណត់។

7.6. លោក-លោកស្រី មានសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការបើក ឬ បិទគណនីបញ្ញើមានកាលកំណត់ កម្រៃសេវា អត្រាការប្រាក់ ពន្ធកាត់ទុក ជាដើម។

7.7. លោក-លោកស្រី មានសិទ្ធិសាកសួរព័ត៌មាន និងការបញ្ជាក់បន្ថែម ក្នុងករណីដែលលោក-លោកស្រីពិនិត្យឃើញពីភាពមិនស៊ីគ្នានៃរបាយការណ៍គណនី ឬ មានចម្ងល់នានាពាក់ព័ន្ធនឹងការបើក ឬ ប្រើប្រាស់គណនីបញ្ញើមានកាលកំណត់ បាននៅគ្រប់សាខាខេប៊ីប្រាសាក់ ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ដោយខេប៊ីប្រាសាក់។

8. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

8.1. ខេប៊ីប្រាសាក់ មានសិទ្ធិផ្ទៀងផ្ទាត់ និងពិនិត្យពីប្រវត្តិរូបរបស់ លោក-លោកស្រី ហើយអាចទាមទារព័ត៌មានផ្ទាល់ខ្លួនបន្ថែមរបស់លោក-លោកស្រី និងមានសិទ្ធិសម្រេចលើការផ្តល់ ឬ មិនផ្តល់សេវាជូន លោក-លោកស្រី។

8.2. ខេប៊ីប្រាសាក់ នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការរបស់លោក-លោកស្រី តែ ខេប៊ីប្រាសាក់ មិនទទួលខុសត្រូវករណី លោក-លោកស្រី បានបញ្ចូល និង/ឬ ជ្រើសរើសខុស លេខគណនីប្រភព និង/ឬ ទំហំទឹកប្រាក់បញ្ញើ និង/ឬ ការខាតបង់ការប្រាក់ដែលបណ្តាលមកពីការស្នើសុំបិទគណនីមុនកាលកំណត់ និង/ឬ ខុសលក្ខខណ្ឌផ្សេងៗជាដើម។ល។

8.3. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការបង្ខាំង ឬ ដោះបង្ខាំង ឬ មិនអនុញ្ញាតឱ្យបន្ត ឬ បន្ត ឬ បិទគណនីមុនកាលកំណត់ ករណី លោក-លោកស្រី មិនបានបំពេញព័ត៌មាន និង/ឬ លក្ខខណ្ឌ ឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ ទៅតាមលក្ខខណ្ឌតម្រូវពី ខេប៊ីប្រាសាក់ និង/ឬ តាមឆន្ទានុសិទ្ធិរបស់ ខេប៊ីប្រាសាក់ ដោយខេប៊ីប្រាសាក់ នឹងមិនទទួលខុសត្រូវលើការខាតបង់ការប្រាក់ និង/ឬ ផលប្រយោជន៍ផ្សេងៗដែលអាចបណ្តាលមកពីការអនុវត្តសិទ្ធិទាំងអស់នេះទេ។

8.4. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការអនុញ្ញាតឱ្យបើក និង/ឬ បិទគណនីបញ្ញើមានកាលកំណត់ ដោយយោងលើវិធាននៃច្បាប់ ឬ ដីការពីតុលាការ។

8.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងផ្អាកប្រតិបត្តិការលើការបើក និង/ឬ បិទគណនីបញ្ញើមានកាលកំណត់ ករណីមានបញ្ហាបច្ចេក ទេស និង/ឬ ពេលមានការចាំបាច់ណាមួយជាដើម។

8.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ អត្រាការប្រាក់ កម្រៃសេវា និង/ឬ លក្ខខណ្ឌផ្សេងៗ អាស្រ័យលើស្ថានភាពនៃអាជីវកម្មជាក់ស្តែង។

8.7. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់លោក-លោកស្រី លើកលែងតែច្បាប់តម្រូវ ឬ ដីការពីតុលាការ ឬ មានការយល់ព្រមពីលោក-លោកស្រី។

8.8. ខេប៊ីប្រាសាក់ ផ្តល់លេខទូរស័ព្ទសម្រាប់បម្រើសេវាកម្ម 24 ម៉ោង ហើយផ្តល់សេវាប្រឹក្សាអំពីសេវាកម្ម ឬ ការរាយការណ៍ ឬ បញ្ហាផ្សេងៗដែលកើតមានឡើង។

9. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អនុលោមតាមបទប្បញ្ញត្តិទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូនម្ចាស់គណនីបាន ប្រសិនបើ ខេប៊ីប្រាសាក់មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

- ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់បញ្ញើនោះ
- ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
- មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។

10. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា លក្ខខណ្ឌ និងការជូនដំណឹង

10.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ អត្រាការប្រាក់ កម្រៃសេវា និងលក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់គណនីរបស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅលោក-លោកស្រី ឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

10.2. ក្នុងរយៈពេលនៃការជូនដំណឹង ករណីមិនមានការតវ៉ាពីលោក-លោកស្រី ត្រូវសន្មតថាអតិថិជនបានយល់ព្រម និងទទួលយកការកែប្រែខាងលើមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមាន ដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1). តាមរយៈសាខារបស់ ខេប៊ីប្រាសាក់ និង/ឬ
2). តាមរយៈវេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ
3). ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី
4). តាមរយៈការផ្សព្វផ្សាយនៅលើទំព័រការសែត ទស្សនាវដ្តី សេវាខេប៊ីប្រាសាក់ម៉ូបាល សេវាខេប៊ីប្រាសាក់ខបភើរេត ឬ មធ្យោបាយផ្សេងៗដែល ខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

10.3. អតិថិជនត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពី ខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួន តាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

11. ច្បាប់ និងការដោះស្រាយវិវាទ

11.1. លក្ខខណ្ឌទូទៅនេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

11.2. ករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធី។ ករណីវិវាទមិនអាចដោះស្រាយបានដោយសន្តិវិធី ឬ ក្រៅប្រព័ន្ធតុលាការ នោះវិវាទត្រូវដោះស្រាយទៅតាមប្រព័ន្ធតុលាការដោយយោងទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

11.3. បញ្ហាផ្សេងៗដែលមិនមានចែងនៅក្នុងប្រការទាំងនេះ ត្រូវអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

11.4. រាល់លក្ខខណ្ឌផ្សេងៗដែលមិនមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះ ត្រូវអនុវត្តដោយយោងទៅតាម **«លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ខេប៊ីប្រាសាក់»** ដែល លោក-លោកស្រី អាចស្វែងរកបាននៅតាមវេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ឬ តាមសាខា ខេប៊ីប្រាសាក់ណាមួយដែលនៅជិត លោក-លោកស្រី បំផុត។

12. វិភាគភាព

ប្រសិនបើប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

13. ភាសា

លក្ខខណ្ឌនេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ៕